ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២១១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលទំហំផ្ទៃដីសម្បទានសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ មានទីតាំងស្ថិតនៅឃុំរាម អូរឧកញ៉ាហេង ព្រៃនប់ ទួលទទឹង អណ្តូងថ្ម សំរ៉ុង នៃស្រុកព្រៃនប់ និងឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ២៥២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០១១ ស្តីពីការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៧ ១០០ ហិកតា ស្ថិតក្នុងឃុំរាម អូរឧកញ៉ាហេង ព្រៃនប់ ទួលទទឹង អណ្តូងថ្ម សំរ៉ុង នៃស្រុកព្រៃនប់ និងឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ

- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលទំហំផ្ទៃដីសម្បទានសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ មានទីតាំងស្ថិតនៅឃុំរាម អូរឧកញ៉ាហេង ព្រៃនប់ ទួលទទឹង អណ្តូងថ្ម សំរុង នៃស្រុកព្រៃនប់ និងឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

ឆ្លៀលចេញនូវផ្ទៃដីទំហំ ៤៦ ហិកតា ៦៣ អា ៣២ សង់ទីអា ស្ថិតនៅភូមិ១ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលទំហំផ្ទៃដីសម្បទានសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ មានទីតាំងស្ថិតនៅឃុំរាម អូរឧកញ៉ាហេង ព្រៃនប់ ទួលទទឹង អណ្តូងថ្ម សំរុង នៃស្រុកព្រៃនប់ និងឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងផ្តល់ជាកម្មសិទ្ធិជូនឈ្មោះ **ផឹង សុខា** និងឈ្មោះ **ជា ស្រីតូច** ដែលបានកាន់កាប់ជាក់ស្តែង និងអាស្រ័យផលពីមុនមក។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៤កើត ខែបុស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីនិងតារាងនិយាមការឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២១១ អនក្រ.បក ចុះថ្ងៃទី១៨.....ខែ ធ្នូ.....ឆ្នាំ២០២០




តារាងនិយាមការព្រំដីកាត់ចេញពីដីសម្បទានសង្គមកិច្ចកំណត់ដោយអនុក្រឹត្យលេខ ៥២

Projection, UTM,Zone 48N

Datum,WGS,1984

| ID | E | N |
|---|---|---|
| 1 | 357364.455 | 1184395.046 |
| 2 | 357819.374 | 1184051.610 |
| 3 | 357468.994 | 1183587.495 |
| 4 | 357147.800 | 1183833.270 |
| 5 | 356927.430 | 1183545.278 |
| 6 | 356828.619 | 1183685.277 |
| 7 | 356790.621 | 1184497.984 |
| 8 | 356616.000 | 1184657.000 |
| 9 | 356601.000 | 1184729.000 |
| 10 | 356564.593 | 1184844.925 |
| 11 | 356620.680 | 1184904.269 |
| 12 | 356822.448 | 1184805.025 |
| 13 | 356938.662 | 1184694.080 |

ផែនទីបង្ហាញទីតាំងដីទំហំសរុប ៤៦ ហិកតា ៦៣ អា ៣២ សង់ទីអា ស្ថិតនៅភូមិ១ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ស្នើសុំកាត់ចេញ ពីដីសម្បទានសង្គមកិច្ចកំណត់ដោយអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០១៦ ជូនឈ្មោះ ឆឹង សុខា និងឈ្មោះ ជា ស្រីនុច




តារាងនិយាមកាព្រំដីស្នើសុំកាត់ចេញពីដីសម្បទានសង្គមកិច្ចកំណត់ដោយអនុក្រឹត្យលេខ ៥២

Projection, UTM,Zone 48N

Datum,WGS,1984

| ID | E | N |
|---|---|---|
| 1 | 357364.455 | 1184395.046 |
| 2 | 357819.374 | 1184051.610 |
| 3 | 357468.994 | 1183587.495 |
| 4 | 357147.800 | 1183833.270 |
| 5 | 356927.430 | 1183545.278 |
| 6 | 356828.619 | 1183685.277 |
| 7 | 356790.621 | 1184497.984 |
| 8 | 356616.000 | 1184657.000 |
| 9 | 356601.000 | 1184729.000 |
| 10 | 356564.593 | 1184844.925 |
| 11 | 356620.680 | 1184904.269 |
| 12 | 356822.448 | 1184805.025 |
| 13 | 356938.662 | 1184694.080 |